# កិច្ចប្រជុំពិនិត្យ និងផ្ទៀងផ្ទាត់តួលេខអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដែលគួរទទួលបានប័ណ្ណក្រីក្រនៅក្នុង៨ខេត្តដំបូង ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦

ការជួយគាំទ្រផ្នែកសង្គមដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ តាមរយៈការផ្តល់ជូនប័ណ្ណក្រីក្រ ដើម្បីទទួលបាននូវសេវាសាធាណៈនៅតាមមូលដ្ឋាន គឺពិតជាមានសារៈសំខាន់។ ដើម្បីអោយកិច្ចការនេះទទួលបានជោគជ័យ កាលពីល្ងាចថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន បានជួបប្រជុំជាមួយបុគ្គលិករបស់អង្គការ Women , CRS និងបណ្តាញ CPN+ ដែលជាអង្គការសង្គមស៊ីវិលធ្វើកិច្ចការនេះនៅថ្នាក់ក្រោមជាតិ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់តួលេខអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដែលគួរទទួលបានប័ណ្ណក្រីក្រនៅក្នុង៨ខេត្តដំបូង សំរាប់រៀបចំផ្ញើជូនទៅក្រសួងផែនការ ។

ជាលទ្ធផលអង្គប្រជុំបានឯកភាពកែសម្រួលតួលេខមួយចំនួន អោយសមស្របតាមទិសដៅដែលបានកំណត់ដោយក្រសួងផែនការតម្រូវអោយអនុវត្តមួយជំហានម្តងៗ។



